អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
អគ្គនាយកដ្ឋានស្រាវជ្រាវ
នាយកដ្ឋានស្រាវជ្រាវថវិកា

# ព្រឹត្តិបត្រព័ត៌មានថវិកា និងសេដ្ឋកិច្ច

**មាតិកា៖**

- ធនាគារពិភពលោក (WB) បានអនុម័តនូវកញ្ចប់ឥណទាន ចំនួន ២០០លានដុល្លារ មកប្រទេសកម្ពុជា
- រយៈពេល៥ខែកម្ពុជាសម្រេចការនាំចេញទំនិញជិត១៤០លានដុល្លារសហរដ្ឋអាមេរិកទៅកាន់ប្រទេសកូរ៉េខាងត្បូង
- កម្ពុជា សម្រេចដាក់ឱ្យដំណើរការផែនការសកម្មភាពជាតិ សេដ្ឋកិច្ចវិលជុំ
- តំបន់អាទិភាពចំនួន៦ក្នុងខេត្តខេត្តមណ្ឌលគីរី ត្រូវបានកំណត់ក្នុងផែនការមេសម្រាប់អភិវឌ្ឍន៍ទេសចរណ៍
- តុល្យភាពពាណិជ្ជកម្មរបស់ប្រទេសម៉ាឡេស៊ីអតិរេក ៣២,៣% ក្នុងខែឧសភាឆ្នាំ២០២១
- ម៉ាឡេស៊ីប្រកាសកញ្ចប់ជំរុញសេដ្ឋកិច្ចថ្មី ដើម្បីជួយសម្រួលដល់ផលប៉ះពាល់ពីការបន្តការបិទខ្ទប់ប្រទេសទាំងស្រុង
- ថៃ បាត់បង់ការងារក្នុងវិស័យទេសចរណ៍ ប្រមាណ៥៥០ ០០០កន្លែងបន្ទាប់ពីមានរលកថ្មីនៃជំងឺកូវីឌ១៩
- ធនាគារកណ្តាលថៃព្យាករណ៍ថា សេដ្ឋកិច្ចនឹងវិលត្រលប់ទៅរកកម្រិតមុនវិបត្តិវិញ នៅត្រីមាសទី១ឆ្នាំ២០២៣
- ចិន បញ្ជាទិញអង្ករ ២ម៉ឺនតោនពី ថៃ ក្រោមកិច្ចព្រមព្រៀងរដ្ឋាភិបាលទ្វេភាគី
- សូចនាករអតិផរណាគន្លិះ មានកំណើនខ្ពស់ក្នុងឆ្នាំចុងក្រោយនេះ ធៀបនឹងអំលុងជិតបីទសវត្សរ៍កន្លងមក
- បំណុលរបស់ចិន មានការកើនឡើងយ៉ាងគំហុក
- អត្រាគ្មានការងារធ្វើនៅប្រទេសជប៉ុន កើនឡើងដល់៣% នៅក្នុងខែឧសភា

ពិនិត្យ និងកែសម្រួលដោយ

- សួន ពុធថាវី អគ្គនាយិកា នៃអគ្គនាយកដ្ឋានស្រាវជ្រាវ
- គឹម សុចិត្រា អគ្គនាយករង នៃអគ្គនាយកដ្ឋានស្រាវជ្រាវ
- ណុប ចាន់ធី ប្រធាននាយកដ្ឋានស្រាវជ្រាវថវិកា
- ម៉ែន ខែមរៈ អនុប្រធាននាយកដ្ឋានស្រាវជ្រាវថវិកា

# ព័ត៌មាន និងទិន្នន័យអំពីប្រទេសកម្ពុជា

## ធនាគារពិភពលោក(WB) បានអនុម័តកញ្ចប់ឥណទាន ចំនួន ២០០លានដុល្លារមកប្រទេសកម្ពុជា




*ប្រភព៖ postkhmer, 2021 រូបភាព៖ ហេង ជីវ័ន*

ធនាគារពិភពលោក(World Bank) បានអនុម័តកញ្ចប់ឥណទាន មកប្រទេសកម្ពុជា ចំនួន ២០០ លានដុល្លារ ក្នុងគោលបំណងជួយគាំទ្រដល់រាជរដ្ឋាភិបាលដើម្បីប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ រួមទាំងការជួយកសាងភាពធន់ និងការស្តារសេដ្ឋកិច្ចប្រទេសឱ្យងើបឡើងវិញ។ ការរៀបចំគម្រោងគោលនយោបាយហិរញ្ញប្បទានរបស់ធនាគារពិភពលោក នឹងជួយដល់កម្ពុជាដើម្បីដោះស្រាយវិបត្តិកូវីដ-១៩ តាមរយៈកិច្ចអន្តរាគមន៍សង្គ្រោះទាន់ពេលវេលា នឹងចំគោលដៅ សម្រាប់ប្រជាពលរដ្ឋក្រីក្រ និងងាយរងគ្រោះ។ បន្ថែមពីនេះ ហិរញ្ញប្បទាននឹងជួយទប់ទល់ផលប៉ះពាល់ផ្នែកសេដ្ឋកិច្ច និងការស្តារសេដ្ឋកិច្ចឱ្យងើបឡើងវិញនាពេលខាងមុខផងដែរ នេះបើយោងតាមសេចក្តីប្រកាសព័ត៌មានរបស់ធនាគារពិភពលោក។ សូមបញ្ជាក់ផងដែរ គម្រោងនេះគឺជាផ្នែកស្នូលមួយនៃអន្តរាគមន៍ទូលំទូលាយរបស់ធនាគារពិភពលោក ក្នុងការឆ្លើយតបទៅនឹងវិបត្តិកូវីដ-១៩ ហើយក៏ជាផ្នែកមួយនៃកញ្ចប់ប្រតិបត្តិការទ្រទ្រង់ថវិកាពីសំណាក់ដៃគូអភិវឌ្ឍន៍មួយចំនួនរបស់កម្ពុជា មានដូចជា ធនាគារអភិវឌ្ឍន៍អាស៊ី សហភាពអឺរ៉ុប និងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA)។

ចាប់តាំងពីផ្ទុះការរាតត្បាតជំងឺកូវីដ១៩មក ក្រុមធនាគារពិភពលោក បានសន្យាផ្តល់ជំនួយជាង ១២៥ ប៊ីលានដុល្លារ ដល់ប្រទេសចំនួនជាង១០០ សម្រាប់ផ្នែកសុខាភិបាល សេដ្ឋកិច្ច និងសង្គម ដែលមានទំហំធំ និងមិនធ្លាប់មាននៅក្នុងប្រវត្តិសាស្ត្រ។

ទន្ទឹមនឹងនេះ ធនាគារពិភពលោកបានផ្តល់ហិរញ្ញប្បទានចំនួន ១២ ប៊ីលានដុល្លារផ្សេងទៀតដល់បណ្តាប្រទេសមានចំណូលទាប មធ្យម សម្រាប់ទិញសម្ភារៈ បរិក្ខាធ្វើតេស្ត និងវ៉ាក់សាំងជាដើម ដើម្បីប្រយុទ្ធប្រឆាំងនឹងការរាតត្បាតនៃជំងឺកូវីដ-១៩ ។

គិតចាប់ពីថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២០ ដល់ថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ២០២១នេះ រាជរដ្ឋាភិបាលកម្ពុជាបានចំណាយថវិការដ្ឋជាង ៣៥១,៧៧លានដុល្លារ សម្រាប់ជួយដល់គ្រួសារក្រីក្រ ប្រមាណជិត៧០ម៉ឺនគ្រួសារ ឬជាង ២,៧ លាននាក់ដែលរងផលប៉ះពាល់ដោយសារជំងឺកូវីដ-១៩៕ *ដោយ សេន ចន្ទូ*

*ប្រភព៖ postkhmer.ចេញផ្សាយថ្ងៃទី២៨ខែមិថុនា ឆ្នាំ២០២១*

## រយៈពេល៥ខែ កម្ពុជាសម្រេចការនាំចេញទំនិញជិត ១៤០លានដុល្លារសហរដ្ឋអាមេរិក ទៅកាន់ប្រទេសកូរ៉េខាងត្បូង



*ប្រភព៖ ព័ត៌មាន PNN ២០២១* និងរូបភាពឯកសារ

ក្នុងរយៈពេល ៥ខែ ដើមឆ្នាំ២០២១នេះ ប្រទេសកម្ពុជា សម្រេចបាននូវការនាំចេញទំនិញ ក្នុងទំហំទឹកប្រាក់ប្រមាណ១៤០លានដុល្លារអាមេរិក ទៅកាន់ប្រទេសកូរ៉េខាងត្បូង កើនឡើង០,៤% ធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន។ គិតចាប់ពីខែមករា ដល់ខែមេសា ការនាំចេញទំនិញពីកម្ពុជា ទៅកាន់ទីផ្សារកូរ៉េ រក្សាកំណើនវិជ្ជមាន ទើបតែក្នុងខែឧសភា ការនាំចេញរបស់កម្ពុជាបានធ្លាក់ចុះដល់ទៅ៤១% ធៀបនឹងពេលដូចគ្នាកាលពីឆ្នាំមុន។

ការនាំចេញពីកម្ពុជា ទៅកូរ៉េខាងត្បូង ភាគច្រើនជាផលិតផលកសិកម្ម សម្លៀកបំពាក់ និងគ្រឿងបង្គុំអេឡិចត្រូនិក ហើយកូរ៉េខាងត្បូង ក៏បាននាំចេញមកកម្ពុជាមានតម្លៃសរុប ២៣៧លានដុល្លារអាមេរិក កើនដល់ទៅ១០% ធៀបនឹងពេលដូចគ្នាកាលពីឆ្នាំ២០២០ ដែលមានផលិតផលសំខាន់ៗដូចជា រថយន្ត គ្រឿងអេឡិចត្រូនិក គេសជ្ជៈ និងឱសថជាដើម។

គិតចាប់ពីខែមករា ដល់ខែឧសភា ឆ្នាំ២០២១កន្លងទៅនេះ ទំហំពាណិជ្ជកម្មរវាង កម្ពុជា និងកូរ៉េខាងត្បូង មានប្រមាណ ៣៧៧លានដុល្លារអាមេរិក(កម្ពុជាមានឱនភាពពាណិជ្ជកម្មប្រមាណជា៩៧លានដុល្លារអាមេរិក)។

ឯកឧត្តមរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មកម្ពុជា ជឿជាក់ថាទំហំពាណិជ្ជកម្មទ្វេភាគីរវាងប្រទេសទាំងពីរនឹងកើនឡើងលើស ១ពាន់លានដុល្លារអាមេរិក ក្នុងពេលឆាប់ៗខាងមុខ ហើយនឹងបន្តកំណើនលូតលាស់ជាលំដាប់ ក្រោយពេលដែលកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-កូរ៉េខាងត្បូង ចូលជាធរមាន៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព៖ PNN ចេញផ្សាយថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២១*

## កម្ពុជា សម្រេចដាក់ឱ្យដំណើរការផែនការសកម្មភាពជាតិ សេដ្ឋកិច្ចវិលជុំ




*ប្រភព៖ ភ្នំពេញប៉ុស្តិ៍ ២០២១ , រូបភាព៖ សហការី*

រាជរដ្ឋាភិបាលកម្ពុជា ដោយមានការគាំទ្រពីដៃគូអភិវឌ្ឍន៍នានា បានដាក់ឱ្យដំណើរការផែនការសកម្មភាពជាតិសេដ្ឋកិច្ចវិលជុំ និងនិតិវិធីដើម្បីជំរុញការចូលរួមពីវិស័យឯកជន ក្នុងអន្តរកាលឆ្ពោះទៅរកសេដ្ឋកិច្ចវិលជុំ ខណៈដែលកំណើនសេដ្ឋកិច្ច និងកំណើនប្រជាជននៅកម្ពុជាបាននាំមកនូវបញ្ហាប្រឈមថ្មីៗក្នុងការគ្រប់គ្រងធម្មជាតិបរិស្ថាន ថាមពល និងសំណល់ប្រកបដោយនិរន្តរភាព។ ឯកឧត្តម សាយ សំអាល់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន និងជាប្រធានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព(NCSD)

បានលើកឡើងថា៖ ការដាក់ឱ្យដំណើរការផែនការសកម្មភាពជាតិសេដ្ឋកិច្ចវិលជុំ ដោយមានការគាំទ្រពីប្រទេសស៊ុយអែត ជប៉ុន និងកម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ(UNDP) គឺដើម្បីឆ្លើយតបទៅនឹងកំណើនសេដ្ឋកិច្ច និងកំណើនប្រជាជននៅកម្ពុជា ដែលបានធ្វើឱ្យមានការកើនឡើងនូវការប្រើប្រាស់វត្ថុធាតុដើម និងថាមពល ហើយកំណើននោះបាននាំមកនូវបញ្ហាប្រឈមថ្មីៗក្នុងការគ្រប់គ្រងធម្មជាតិ បរិស្ថាន ថាមពល និងសំណល់។

បន្ថែមពីនេះ យុទ្ធសាស្ត្រ និងផែនការសេដ្ឋកិច្ចវិលជុំ មានគោលបំណង ដោះស្រាយបញ្ហាប្រឈមចំពោះមុខនាពេលបច្ចុប្បន្ន ការលុបបំបាត់ការខ្វះខាតធនធាន នៅក្នុងវដ្តសេដ្ឋកិច្ចទាំងមូល និងបន្តរក្សាសម្ភារៈនានា ឱ្យបានយូរបំផុតតាមដែលអាចធ្វើទៅបាន ជំនួសឱ្យការប្រើប្រាស់រួចហើយបោះចោលតែម្តង។ ទន្ទឹមនឹងនេះ ការអនុវត្តយុទ្ធសាស្ត្រសេដ្ឋកិច្ចវិលជុំប្រកបដោយចីរភាព នឹងធានាឱ្យកម្ពុជាអាចទទួលបានអនាគត ដែលមានភាពបៃតង ស្អាត មានសុវត្ថិភាព ព្រមទាំងបង្កើនតម្លៃសេដ្ឋកិច្ចថ្មី និងឱកាសការងារកាន់តែច្រើនឡើង។

យោងតាមរបាយការណ៍ចុងក្រោយរបស់អង្គការឧតុនិយមពិភពលោក(WMO) សីតុណ្ហភាពពិភពលោក អាចកើនលើសពីការកំណត់ទិសដៅត្រឹម១,៥អង្សារសេ ពីកម្រិតមុនឧស្សាហកម្មក្នុងរយៈពេល៥ឆ្នាំក្រោយ។ នៅទូទាំងភពផែនដី ការកើនឡើងសីតុណ្ហភាពណាមួយនឹងបង្កើនគ្រោះមហន្តរាយអាកាសធាតុយ៉ាងខ្លាំងដូចជាខ្យល់ព្យុះទីហ្វុងធំៗ ទឹកជំនន់ធំៗ ភាពរាំងស្ងួតខ្លាំង និងការបង្កើនភ្លើងឆេះព្រៃ៕ *ដោយ មុំ ចិន្តា*

*ប្រភព៖ ភ្នំពេញប៉ុស្តិ៍ ចេញផ្សាយថ្ងៃទី ២៩ ខែមិថុនា ឆ្នាំ២០២១*

## តំបន់អាទិភាពចំនួន៦ ត្រូវបានកំណត់ក្នុងផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តមណ្ឌលគិរី



*គណៈកម្មាធិការជាតិអភិវឌ្ឍន៍ទេសចរណ៍*

រាជរដ្ឋាភិបាល បានកំណត់យកតំបន់អាទិភាពសំខាន់ៗ ចំនួន៦ សម្រាប់ការអភិវឌ្ឍន៍វិស័យទេសចរណ៍ក្នុងខេត្តមណ្ឌលគិរី។ តំបន់អាទិភាពសំខាន់ៗទាំង ៦ រួមមាន ៖ **ទី១៖** តំបន់របៀងអេកូទេសចរណ៍ និងទេសចរណ៍ធម្មជាតិនៃដែនជម្រកសត្វព្រៃទាំង ៥ (ដែនជម្រកសត្វព្រៃភ្នំព្រេច ណាមលៀរ លំផាត់ កែវសីមា និងស្រែពក) ដែលអនុញ្ញាតឱ្យវិនិយោគ និងអភិវឌ្ឍន៍សកម្មភាពទេសចរណ៍ ត្រូវមានការគិតគូរច្បាស់លាស់អំពីបរិស្ថាន។ **ទី២៖** តំបន់របៀងទេសចរណ៍វប្បធម៌ និងអេកូទេសចរណ៍ប៊ូស្រា-ដាក់ដាំ ដែលលើកទឹកចិត្តឱ្យមានការអភិវឌ្ឍសកម្មភាពអេកូទេសចរណ៍ និងទេសចរណ៍ធម្មជាតិភ្ជាប់ជាមួយទេសចរណ៍វប្បធម៌ជនជាតិដើមភាគតិច។ **ទី៣៖** ក្រុងសែនមនោរម្យ ដែលជាបណ្តុំសកម្មភាពទេសចរណ៍ពហុបំណង។ **ទី៤៖** តំបន់ស្រុកអូររាំង ភ្ជាប់គម្រោងព្រលានយន្តហោះខេត្តមណ្ឌលគិរី ដែលអាចអភិវឌ្ឍន៍ជាតំបន់ប្រជុំជនរណប ភ្ជាប់ជាមួយក្រុងសែនមនោរម្យ។ **ទី៥៖** តំបន់ប្រជុំជននៃស្រុកកោះញែក មានសក្តានុពលអភិវឌ្ឍន៍ជាមណ្ឌលទេសចរណ៍ ក្នុងវិសាលភាពទូលំទូលាយ ជាងក្នុងតំបន់អភិរក្សដែនជម្រកសត្វ

ព្រៃ។ **ទី៦៖** តំបន់ទេសចរណ៍សមាហរណតាមច្រកព្រំដែន ដែលអភិវឌ្ឍជារមណីយដ្ឋានសមាហរណកម្ម។

ផែនការមេ សម្រាប់ការអភិវឌ្ឍវិស័យទេសចរណ៍ខេត្តមណ្ឌលគិរី (២០២១-២០៣៥)នេះ បានកំណត់នូវចក្ខុវិស័យសំខាន់ៗ ដូចខាងក្រោម ៖

*ខេត្តមណ្ឌលគិរី ត្រូវកំណត់ជាគោលដៅអេកូទេសចរណ៍លំដាប់អន្តរជាតិ និងជាខេត្តដ៏សំខាន់ក្នុងការផ្គត់ផ្គង់ ផ្កា បន្លែ និងផ្លែឈើ សម្រាប់លក់ក្នុងប្រទេស និងនាំចេញទៅទីផ្សារក្រៅប្រទេស។

* ឆ្នាំ២០៣៥ ចំនួនភ្ញៀវទេសចរជាតិ និងអន្តរជាតិមកកាន់ខេត្តមណ្ឌលគិរី នឹងមានការកើនឡើង ដែលអាចបង្កើតការងារ និងបង្កើតចំណូលដោយផ្ទាល់ និងដោយប្រយោល ជួយទ្រទ្រង់សេដ្ឋកិច្ចខេត្តមណ្ឌលគិរី និងសេដ្ឋកិច្ចជាតិ។

*ខេត្តមណ្ឌលគិរី ជាប៉ូលសេដ្ឋកិច្ចទី៤ បន្ទាប់ពីរាជធានីភ្នំពេញ តំបន់ឆ្នេរ និងតំបន់សៀមរាប និងអាចធ្វើសមាហរណកម្មខេត្តមណ្ឌលគិរីជាមួយតំបន់ផ្សេងៗ ក្នុងប្រទេស និងក្នុងតំបន់។

*ការអភិវឌ្ឍសេដ្ឋកិច្ច ទេសចរណ៍ និងអន្តរវិស័យគាំទ្រជាមួយការអភិរក្សធនធានធម្មជាតិ បេតិកភណ្ឌវប្បធម៌ជនជាតិដើមភាគតិច ជានាបានផ្លែផ្កានៃការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមជាអតិបរមា ឈរលើគោលការណ៍នៃការបែងចែកផលប្រយោជន៍ប្រកប ដោយសមធម៌ទៅដល់ភាគីពាក់ព័ន្ធ។

ផែនការមេនេះ មានលក្ខណៈជាផែនការសមាហរណកម្មជាមួយអន្តរវិស័យគាំទ្រសំខាន់ៗមួយចំនួន ដើម្បីជាត្រីវិស័យដ៏សំខាន់ ចង្អុលបង្ហាញយន្តការ និងទិសដៅយុទ្ធសាស្ត្រសំខាន់ៗ ដើម្បីឆ្លើយតបនឹងចក្ខុវិស័យនៃការអភិវឌ្ឍជាតិក្នុងរយៈពេល៥ឆ្នាំ(២០២១-២០៣៥) និងបណ្តាឆ្នាំខាងមុខ ដោយផ្អែកលើស្ថានភាពបច្ចុប្បន្ន និងការប្តេជ្ញាចិត្តច្បាស់លាស់របស់រាជរដ្ឋាភិបាល ដោយផ្តោតលើគោលបំណងសំខាន់ ៣ គឺ ៖

**ទី១៖** ខេត្តមណ្ឌលគិរី ជាគោលដៅទេសចរណ៍ប្រកបដោយគុណភាព ប្រកបដោយឧត្តមានុវត្តន៍។

**ទី២៖** ខេត្តមណ្ឌលគិរី ជាមជ្ឈមណ្ឌលសេដ្ឋកិច្ចប្រកបដោយភាពឆ្លាតវៃ និងច្នៃប្រឌិត និងជាមជ្ឈមណ្ឌលសម្រាប់តំបន់ភាគឦសាន។

**ទី៣៖** ខេត្តមណ្ឌលគិរី ជាខេត្តដែលមានការគិតគូរច្បាស់លាស់នូវទស្សនទាន«ការអភិរក្សដើម្បីការអភិវឌ្ឍ ហើយការអភិវឌ្ឍទ្រទ្រង់ដល់ការអភិរក្ស»៕ *ដោយ ម៉ែន ខែមវរៈ*

*ប្រភព៖ Fress News ចេញផ្សាយថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២១*

## តារាងប្រចាំសប្តាហ៍ ៖

### តារាងទី១៖ ការចំណាយលើអត្ថប្រយោជន៍សង្គមប្រចាំខែមេសា ឆ្នាំ២០២១

តាមទិន្នន័យរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុកម្ពុជា បង្ហាញថា៖ នៅក្នុងខែមេសា ឆ្នាំ២០២១ រដ្ឋបាលថ្នាក់ជាតិ បានចំណាយលើអត្ថប្រយោជន៍សង្គមក្នុងទំហំទឹកប្រាក់សរុបចំនួន ១១៤,៩៩ប៊ីលានរៀល ដែលមានការធ្លាក់ចុះប្រមាណជា ៥៣,៨% បើធៀបនឹងខែមីនា។ ជាក់ស្តែង ការចំណាយលើអត្ថប្រយោជន៍សន្តិសុខសង្គម មានទឹកប្រាក់ចំនួន៣៩,០៦ប៊ីលានរៀល នៅខែមេសា ឆ្នាំ២០២១ ដែលមានការធ្លាក់ចុះប្រមាណជា៧៥,៤% ធៀបនឹងខែមីនា។

ទន្ទឹមនឹងនោះដែរ ការចំណាយលើជំនួយសង្គមដល់ប្រជាពលរដ្ឋ មានទឹកប្រាក់ចំនួន ៦៥,៦៥ប៊ីលានរៀល នៅក្នុងខែមេសា ឆ្នាំ២០២១ ដែលមានការធ្លាក់ចុះប្រមាណជា ១២,៨% បើធៀបនឹងខែមីនា។

ផ្ទុយទៅវិញ ការចំណាយលើការឧបត្ថម្ភអង្គភាព ដែលមានលក្ខណៈសង្គម និងវប្បធម៌ មានទឹកប្រាក់ ១០,៥៧ ប៊ីលានរៀលក្នុងខែមេសាឆ្នាំ២០២១ ដែលមានកំណើនប្រមាណជា៥៩,៣%បើធៀបនឹងខែមីនា។ ដោយឡែកការចំណាយអត្ថប្រយោជន៍សង្គមផ្សេងៗទៀតមិនមានទេ នៅខែមេសាឆ្នាំ២០២១នេះ៕ *ដោយ មិត្ត ចន្ធី*

| ការចំណាយឆ្នាំ២០២១ (គិតជាប៊ីលានរៀល) | មករា | កុម្ភៈ | មីនា | មេសា |
|---|---|---|---|---|
| អត្ថប្រយោជន៍សង្គម | 103.40 | 115.26 | 249.05 | 114.99 |
| កំណើន/ថយ(%) | | 11.5% | 116.1% | -53.8% |
| អត្ថប្រយោជន៍សន្តិសុខសង្គម | 90.63 | 101.04 | 158.63 | 39.06 |
| កំណើន/ថយ(%) | | 11.5% | 57.0% | -75.4% |
| ជំនួយសង្គមដល់ប្រជាពលរដ្ឋ | 9.54 | 8.85 | 75.32 | 65.65 |
| កំណើន/ថយ(%) | | -7.2% | 751.1% | -12.8% |
| ឧបត្ថម្ភអង្គភាពដែលមានលក្ខណៈសង្គម និងវប្បធម៌ | 3.23 | 4.83 | 6.64 | 10.57 |
| កំណើន/ថយ(%) | | 49.5% | 37.5% | 59.2% |
| អត្ថប្រយោជន៍សង្គមផ្សេងៗទៀត | - | - | - | - |

*ប្រភព៖តារាងប្រតិបត្តិការហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សម្រាប់ខែមេសាឆ្នាំ២០២១*

## តារាងទី២ ៖ ពាណិជ្ជកម្មរវាងកម្ពុជា និងប្រទេសថៃលើមុខទំនិញ នៅក្នុងខែមេសា ឆ្នាំ២០២០១

យោងទៅតាមទិន្នន័យរបស់ធនាគារប្រទេសថៃ បានបង្ហាញថា៖ នៅក្នុងខែមេសា ឆ្នាំ២០២១ ទំហំពាណិជ្ជកម្មរវាងប្រទេសកម្ពុជា និងប្រទេសថៃ មានទឹកប្រាក់ទំហំប្រមាណជា ៥៩៦,៦១លានដុល្លារ ដែលមានការធ្លាក់ចុះប្រមាណជា ២៥,៣% បើធៀបនឹងខែមីនា។

ជាក់ស្តែង នៅក្នុងខែមេសា ឆ្នាំ២០២១ ការនាំចេញទំនិញរបស់កម្ពុជាទៅប្រទេសថៃ មានទំហំទឹកប្រាក់ប្រមាណជា ៧២,៦៣លានដុល្លារ ដែលមានការធ្លាក់ចុះប្រហែល ៣០,៣% បើធៀបនឹងខែមីនា។

ស្របពេលនោះដែរ ការនាំចូលទំនិញរបស់ប្រទេសថៃមកកម្ពុជាមានទំហំទឹកប្រាក់ ៥២៣,៩៨លានដុល្លារ នៅក្នុងខែមេសាឆ្នាំ២០២១ដែលមានការធ្លាក់ចុះប្រមាណជា២៤,៦% បើធៀបនឹងខែមីនា៕ *ដោយ មិត្ត ចន្ធី*

***ឯកតា៖ គិតជាលានដុល្លារអាមេរិក***

| បរិយាយ | មករា | កុម្ភៈ | មីនា | មេសា |
|---|---|---|---|---|
| **ទំហំពាណិជ្ជកម្ម** | **653.39** | **644.76** | **799.19** | **596.61** |
| កំណើន% | | -1.3% | 24.0% | -25.3% |
| នាំចេញ | 113.22 | 112.05 | 104.27 | 72.63 |
| កំណើន% | | -1.0% | -6.9% | -30.3% |
| នាំចូល | 540.17 | 532.71 | 694.92 | 523.98 |
| កំណើន% | | -1.4% | 30.4% | -24.6% |

ប្រភព៖ *ធនាគារប្រទេសថៃ*

## ព័ត៌មាន និងទិន្នន័យរបស់បណ្តាប្រទេសនៅក្នុងអាស៊ាន និងដៃគូពាណិជ្ជកម្មដទៃទៀត

### តុល្យភាពពាណិជ្ជកម្មរបស់ប្រទេសម៉ាឡេស៊ី អតិរេក ៣២,៣% ក្នុងខែឧសភា ឆ្នាំ២០២១

យោងតាមទិន្នន័យពីនាយកដ្ឋានស្ថិតិរបស់ម៉ាឡេស៊ី (Department of statistics Malaysia official Portal) បង្ហាញថា តុល្យភាពពាណិជ្ជកម្មរបស់ម៉ាឡេស៊ីក្នុងខែឧសភាឆ្នាំ២០២១មានអតិរេកចំនួន RM១៣ ៧៤៣ លានកើនឡើង ៣២,៣% ធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំកន្លងទៅ។

ការនាំចេញរបស់ម៉ាឡេស៊ីក្នុងខែឧសភា ឆ្នាំ២០២១នេះ នៅតែមានកម្រិតខ្ពស់ បានកើនឡើង៤៧,៣% ធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំកន្លងទៅ ដែលមានតម្លៃសរុបចំនួន RM ៩២ ៣១៣ លាន។

ចំណែកឯការនាំចូលវិញមានតម្លៃសរុបរហូតដល់ RM៧៨ ៥៧០ លាន កើនឡើង ៥០,៣% ធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន៕ *ដោយ មុំ ចិន្តា*

**តារាងប្រតិបត្តិការពាណិជ្ជកម្មរបស់ម៉ាឡេស៊ី ឆ្នាំ២០២១ (គិតជាលានរីងហ្គីដ RM)**

| បរិយាយ | | មករា | កុម្ភៈ | មីនា | មេសា | ឧសភា |
|---|---|---|---|---|---|---|
| 2020 | នាំចេញ | 84,114 | 74,451 | 80,119 | 64,787 | 62,650 |
| | នាំចូល | 72,081 | 61,832 | 67,805 | 68,420 | 52,263 |
| | តុល្យភាព | *12,033* | *12,619* | *12,314* | *(3,634)* | *10,387* |
| 2021 | នាំចេញ | 89,625 | 87,567 | 104,998 | 105,590 | 92,313 |
| | នាំចូល | 73,023 | 69,690 | 80,794 | 85,231 | 78,570 |
| | តុល្យភាព | *16,603* | *17,877* | *24,204* | *20,359* | *13,743* |
| កំណើតុល្យភាព | | 38.0% | 41.7% | 96.6% | -660.3% | 32.3% |
| %ប្រចាំខែ | នាំចេញ | 6.6% | 17.6% | 31.1% | 63.0% | 47.3% |
| | នាំចូល | 1.3% | 12.7% | 19.2% | 24.6% | 50.3% |

*ប្រភព៖ Department of statistic Malaysia official Portal*

## ម៉ាឡេស៊ីប្រកាសពីកញ្ចប់ជំរុញសេដ្ឋកិច្ចថ្មី ដើម្បីជួយសម្រួលដល់ផលប៉ះពាល់ពីការបន្តការបិទខ្ទប់ប្រទេសទាំងស្រុង



*ប្រភព៖ AFP ២០២១ រូបភាព៖ REUTERS/Lim Huey Teng*

នៅថ្ងៃទី២៨ ខែមិថុនានេះ នាយករដ្ឋមន្ត្រីម៉ាឡេស៊ី លោក Muhyiddin Yassin បានប្រកាសពីកញ្ចប់ជំរុញសេដ្ឋកិច្ចថ្មីមួយ ឈ្មោះថា «កញ្ចប់ការពារប្រជាជន និងការងើបឡើងវិញសេដ្ឋកិច្ច» មានតម្លៃប្រមាណជា ១៥០ ប៊ីលានរីងហ្គិត (ឬស្មើនឹង ៣៦,២ប៊ីលានដុល្លារ) ដើម្បីជួយដល់ប្រជាជន ក្នុងការដោះស្រាយបញ្ហាលំបាកផ្នែកហិរញ្ញវត្ថុ ដែលបង្កឡើងដោយវិបត្តិជំងឺកូវីដ-១៩ ខណៈដែលម៉ាឡេស៊ីសម្រេចពន្យារពេលបន្តការបិទខ្ទប់ប្រទេសទាំងស្រុង រហូតដល់ករណីឆ្លងប្រចាំថ្ងៃ ធ្លាក់ចុះមកក្រោម ៤ពាន់ករណី។

ទន្ទឹមនេះដែរ លោកក៏បានលើកពីសារៈសំខាន់ក្នុងការបន្តផ្តល់ជំនួយហិរញ្ញវត្ថុ ទៅដល់ប្រជាជន ដរាបណាវិបត្តិនៅតែបន្តមាន។ លោកបានគូសបញ្ជាក់ថា ថវិកាប្រមាណជា ៤,៦ប៊ីលានរីងហ្គិត នឹងត្រូវបានលៃលកទុកប្រើប្រាស់ក្នុងគម្រោងជំនួយកូវីដ-១៩ពិសេស ទៅដល់ប្រជាជនចំនួន ១១លាននាក់ (ភាគច្រើនផ្តោតលើមនុស្សចាស់ជរា និងអ្នកមិនទាន់រៀបការ)។ ចំណែកឯថវិកាចំនួន ៥០០លានរីងហ្គិត នឹងត្រូវទុកសម្រាប់ផ្តល់ប្រជាជន ដែលបាត់បង់ចំណូលដោយសារវិបត្តិជំងឺកូវីដ-១៩(ប្រមាណជា ១លានប្រជាជន)។

បន្ថែមពីនេះ រដ្ឋាភិបាលម៉ាឡេស៊ី នឹងផ្តល់ការបញ្ចុះតម្លៃអគ្គិសនី ចន្លោះពី ៥% ទៅ ៤០% ដើម្បីជួយទៅដល់គ្រួសារលើបន្ទុកចំណាយអគ្គិសនី (ក្នុងកម្រិតអតិបរមា ៩០០គីឡូវ៉ាត់ម៉ោង ក្នុងមួយខែ ចាប់ពីខែកក្កដា ទៅដល់ខែកញ្ញា)។ រីឯ សម្រាប់អាជីវកម្មធុនតូច និងមធ្យម រដ្ឋាភិបាលបានសន្យាក្នុងការទូទាត់បន្ថែមក្រោមគម្រោង Prihatin ពិសេស៕ *ដោយ **ជា សិរីរតន៍***

*ប្រភព៖ CNA ចេញផ្សាយ ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២១*

## ថៃ បាត់បង់ការងារក្នុងវិស័យទេសចរណ៍ប្រមាណ ៥សែនកន្លែងក្នុងត្រីមាសទី២បន្ទាប់ពីរលកថ្មីនៃជំងឺ COVID-19




*ប្រភព៖ Fresh News*

ប្រទេសថៃ បានបាត់បង់ការងារលើវិស័យទេសចរណ៍ចំនួន ៥៥០ ០០០កន្លែង នាត្រីមាសទី២ឆ្នាំនេះ ខណៈប្រទេសដែលមានសេដ្ឋកិច្ច ពឹងផ្អែកលើវិស័យទេសចរណ៍មួយនេះ កំពុងតស៊ូនឹងរលកទី៣នៃការផ្ទុះឡើងនៃជំងឺកូវីដ-១៩។

ការផ្ទុះឡើងយ៉ាងធ្ងន់ធ្ងរបំផុតនៃជំងឺកូវីដ-១៩នៅក្នុងប្រទេសថៃ ដែលបានចាប់ផ្តើមឡើងក្នុងខែមេសា បានធ្វើឱ្យប៉ះពាល់យ៉ាងខ្លាំងដល់ការចំណាយ និងការធ្វើដំណើរក្នុងស្រុក ស្របពេលអវត្តមានភ្ញៀវទេសចរបរទេស។ ការផ្ទុះឡើងនៃជំងឺបានបិទប្រមាណ៤០%នៃអាជីវកម្មទេសចរណ៍។ អត្រានៃការស្នាក់នៅសណ្ឋាគារបានធ្លាក់ចុះ១០%ក្នុងត្រីមាសទី២ ពី២០%ក្នុងត្រីមាសទី១។ ចាប់តាំងពីការរាលដាលនៃជំងឺនេះមក កម្មករធ្វើការលើវិស័យទេសចរណ៍ ជាង២លាននាក់ បានបាត់បង់ការងាររបស់ពួកគេ ក្នុងនោះ ៤០០ ០០០នាក់នៅត្រីមាសទី១ឆ្នាំ២០២១។

វិស័យទេសចរណ៍ រំពឹងថា នឹងបើកស្វាគមន៍ភ្ញៀវទេសចរដែលបានចាក់វ៉ាក់សាំងរួច ជាមួយគម្រោងសាកល្បងទៅកម្សាន្តនៅកោះPhuket ដែលអាចនាំភ្ញៀវទេសចរចូលទៅកាន់ប្រទេសថៃ នៅឆ្នាំនេះ៕

*ដោយ ម៉ែន ខេមរៈ*

*ប្រភព៖ Fresh News ចេញផ្សាយថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២១*

## ធនាគារកណ្តាលថៃ ព្យាករណ៍ថាសេដ្ឋកិច្ចនឹងវិលត្រលប់ទៅរកកម្រិតមុនវិបត្តិវិញ នៅត្រីមាសទី១ ឆ្នាំ២០២៣



*ប្រភព៖ CTN News ២០២១*

ធនាគារកណ្តាលថៃ បានលើកឡើងពីការងើបឡើងយឺតនៃវិស័យទេសចរណ៍ បង្កមកពីការកើនឡើងនៃការរាលដាលជំងឺកូវីដ-១៩ និងបានរំពឹងថា សេដ្ឋកិច្ចនឹងអាចវិលត្រលប់ទៅរកកម្រិតមុនវិបត្តិវិញ នៅត្រីមាសទី១ ឆ្នាំ២០២៣។

ទន្ទឹមនេះដែរ ទេសាភិបាលរង លោក Mathee Supapongse បានថ្លែងនៅក្នុងសន្និសីទមួយថា ធនាគារកណ្តាល នឹងតាមដានយ៉ាងជិតដល់លើការវិវត្តនៃស្ថានភាព និងបានត្រៀមរួចរាល់ក្នុងការអនុវត្តគោលនយោបាយចាំបាច់នានា។

ធនាគារកណ្តាល បានបន្ទាបការព្យាករណ៍កំណើនសេដ្ឋកិច្ចរបស់ខ្លួនពី ៣%មកត្រឹម១,៨% សម្រាប់ឆ្នាំ២០២១ ហើយរំពឹងថា ភ្ញៀវទេសចរអន្តរជាតិ នឹងមានត្រឹមតែ ៧០០ពាន់នាក់។ រីឯ ឆ្នាំ២០២២វិញ សេដ្ឋកិច្ច

នឹងមានកំណើន ៣,៩% និងភ្ញៀវទេសចរបរទេសសរុប ១០លាននាក់៕ *ដោយ* ***ជា សិរីរតន៍***

*ប្រភព៖ [Reuters](Reuters) ចេញផ្សាយ ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២១*

## ចិន បញ្ជាទិញអង្ករពីថៃក្រោមកិច្ចព្រមព្រៀងពាណិជ្ជកម្មទ្វេភាគី



*អត្ថបទ៖ ងួន សុភ័ត្រា និងរូបភាពឯកសារ*

ប្រទេសចិន បានសម្រេចបញ្ជាទិញអង្ករ ២ម៉ឺនតោនពីប្រទេសថៃ មានតម្លៃជាង ១០លានដុល្លារ តាមរយៈកិច្ចព្រមព្រៀងរដ្ឋាភិបាលទ្វេភាគី ដោយគ្រោងនឹងដឹកជញ្ជូនក្នុងខែមិថុនា និងខែកក្កដា ឆ្នាំ២០២១នេះ។ ការបញ្ជាទិញនេះ ធ្វើឡើងក្រោយការចរចាជាមួយសហគ្រាសរដ្ឋចិន ដែលត្រួតពិនិត្យកូតានាំចូលអង្ករប្រចាំឆ្នាំរបស់ចិន។ កិច្ចចរចាទិញលក់អង្ករនេះ ក៏ជាផ្នែកមួយនៃផែនការទីផ្សាររវាងក្រសួងពាណិជ្ជកម្មថៃ និងសមាគមអ្នកនាំចេញអង្ករថៃ ដើម្បីជំរុញការនាំចេញអង្ករឱ្យបាន ៦លានតោននៅក្នុងឆ្នាំ២០២១នេះ។

កាលពីចុងឆ្នាំ ២០១៥ សហគ្រាសរដ្ឋចិន បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងទិញអង្ករ ១លានតោនពីប្រទេសថៃ ដែលជាប្រភេទអង្ករប្រមូលផលថ្មីៗនេះ ហើយក្នុងនោះ ៧សែនតោន បានទិញ និងដឹកជញ្ជូនរួចរាល់ហើយ។ ការបញ្ជាទិញអង្ករក្រោមកិច្ចព្រមព្រៀងទ្វេភាគី រវាងថៃ និងចិន ត្រូវបានពន្យារពេលអស់រយៈពេល២ឆ្នាំ ដោយភាគីចិន អះអាងថា អង្ករថៃ មានតម្លៃខ្ពស់ពេក។

ចំពោះកិច្ចព្រមព្រៀងទិញអង្ករថ្មីនេះ គឺមានលក្ខខណ្ឌបត់បែន ដែលអនុញ្ញាតិឱ្យភាគីចិន អាចបញ្ជាទិញអង្ករគ្រប់ប្រភេទពីប្រទេសថៃ ដោយមិនមានកំណត់ចំនួននោះទេ។ លើសពីនេះ ភាគីថៃក៏កំពុងជំរុញឱ្យចិនចុះហត្ថលេខាបញ្ជាទិញអង្ករថៃ ២៨ម៉ឺនតោនទៀត ដែលនៅសល់ក្នុងកុងត្រា ឲ្យបានសម្រេចក្នុងឆ្នាំ ២០២១នេះ។

កាលពីឆ្នាំ ២០២០កន្លងទៅ ភាគីចិន បាននាំចូលអង្ករថៃប្រមាណ ៣៨ម៉ឺនតោន ធ្លាក់ចុះ១៩% ក្នុងតម្លៃសរុប ២៧៧លានដុល្លារអាមេរិក។

រាជរដ្ឋាភិបាលថៃកំពុងមមាញឹកជំរុញការនាំចេញអង្ករថៃឱ្យបាន៦លានតោន ក្នុងឆ្នាំ២០២១នេះ ដោយក្នុងនោះរួមមាន អង្ករស អង្ករផ្កាម្លិះ និងអង្ករចំហុយ៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព ៖ PNN ចេញផ្សាយថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២១*

# សេដ្ឋកិច្ចសកល

## សូចនាករអតិផរណាគន្លឹះ មានកំណើនខ្ពស់ក្នុងមួយឆ្នាំចុងក្រោយនេះ ធៀបនឹងអំលុងជិតបីទសវត្សរ៍កន្លងមក




*រូបថតដោយ៖ [CNBC](CNBC)*

សូចនាករអតិផរណាគន្លឹះដែលធនាគារកណ្តាលរបស់សហរដ្ឋអាមេរិកតែងតែប្រើប្រាស់ ដើម្បីតាក់តែងគោលនយោបាយបានកើនឡើង ៣,៤% ក្នុងខែឧសភា ធៀបនឹងឆ្នាំមុន។ យោងតាមរបាយការណ៍របស់ក្រសួងពាណិជ្ជកម្មបានបង្ហាញថា សូចនាករអតិផរណាគន្លឹះកើនឡើងលឿនបំផុត គិតចាប់តាំងពីដើមទសវត្សរ៍ឆ្នាំ ១៩៩០។ ក្នុងនោះសន្ទស្សន៍ថ្លៃចំណាយលើទំនិញសំខាន់ៗរបស់អ្នកប្រើប្រាស់បានកើនឡើង ដែលការណ៍នេះបានឆ្លុះបញ្ចាំងពីល្បឿនយ៉ាងខ្លាំងក្លា នៃការពង្រីកសេដ្ឋកិច្ច និងសម្ពាធចំណាយ ព្រមទាំងឆ្លុះបញ្ចាំងឱ្យឃើញពីផលប៉ះពាល់បណ្តាលមកពីការបិទខ្ទប់ដោយសារកូវីដ១៩ កាលពីឆ្នាំ២០២០។ ទោះបីជាមានការព្រួយបារម្ភចំពោះពីការកើនអតិផរណា ធនាគារកណ្តាលរបស់សហរដ្ឋអាមេរិកបានអះអាងថា បញ្ហានេះកើតមានតែមួយរយៈពេល ហើយនឹងទំនងបាត់ទៅវិញនៅពេល ដែលស្ថានភាពត្រលប់មករកភាពប្រក្រតីវិញក្តី។ ជាក់ស្តែងនៅក្នុងខែមិថុនានេះ សន្ទស្សន៍ថ្លៃចំណាយផ្ទាល់ខ្លួនកើនឡើង ០,៥% ទាបជាងការព្យាករណ៍ដែលបានរំពឹងទុកថានឹងកើនដល់ ០,៦%។ ដោយធ្វើការបូករួមទាំងតម្លៃអាហារ និងថាមពល សន្ទស្សន៍ថ្លៃចំណាយផ្ទាល់ខ្លួន មានការកើនឡើង ៣,៩% ក្នុងឆ្នាំនេះ និង០,៤% សម្រាប់ខែមិថុនា។ គួរកត់សំគាល់ផងដែរថា អតិផរណាមានការកើនឡើង ដោយសារតែតម្លៃថាមពលបានកើនឡើង ២៧,៤% ខណៈដែលថ្លៃម្ហូបអាហារមានកំណើនត្រឹមតែ ០,៤% ប៉ុណ្ណោះ។ ម្យ៉ាងវិញទៀត ចំណាយរបស់អ្នកប្រើប្រាស់នៅក្នុងខែនេះថេរ ផ្ទុយពីការព្យាករណ៍ដែលបានរំពឹងទុកថានឹងអាចកើនឡើង ០,៤%។ ខណៈដែលចំណូលរបស់ប្រជាពលរដ្ឋបានធ្លាក់ចុះ២% ទាបជាងការព្យាករណ៍ដែលបានរំពឹងទុកថា នឹងអាចធ្លាក់ចុះដល់ទៅ២,៧%។ ចំណែកឯអត្រាប្រាក់សន្សំផ្ទាល់ខ្លួនរបស់ប្រជាពលរដ្ឋ បានកើនឡើង១២,៤% ទាបជាងខែមេសា ដែលអត្រាកំណើននៃប្រាក់សន្សំ មានដល់ទៅ ១៤,៥%៕ *ដោយ វង្ស ច័ន្ទរស្មីដារា*

*ប្រភព៖ គេហទំព័រ CNBC ចេញផ្សាយថ្ងៃទី២៥ ខែមិថុនា ឆ្នាំ ២០២១*

## បំណុលរបស់ចិនមានការកើនឡើងយ៉ាងគំហុក



*ប្រជាពលរដ្ឋចិនកំពុងតែរត់ហាត់ប្រាណនៅសៀងហៃ ថ្ងៃទី១០ ខែមេសា ឆ្នាំ២០២១*
*ប្រភព៖ CNBC រូបថត៖*Qilai Shen | Bloomberg | Getty Images

ក្នុងអំលុងពេលមួយទសវត្សរ៍ចុងក្រោយនេះ បំណុលរបស់ចិនមានការកើនឡើងយ៉ាងគំហុក។ ទីក្រុងប៉េកាំងបានធ្វើការកត់សំគាល់ថា កំណើននៃបំណុលគឺជាការគម្រាមកំហែង ដល់ស្ថិរភាពសេដ្ឋកិច្ចរបស់ចិន។ ប៉ុន្មានឆ្នាំនេះ ចិនបានព្យាយាមកាត់បន្ថយការពឹងផ្អែកលើបំណុលដើម្បីជំរុញកំណើនសេដ្ឋកិច្ច។ ប៉ុន្តែកិច្ចខិតខំប្រឹងប្រែងនេះ ត្រូវបានរាំងស្ទះដោយសារតែកូវីដ១៩។

បំណុលរបស់ចិន បានបង្ករកើនឡើងយ៉ាងឆាប់រហ័សបន្ទាប់ពីវិបត្តិហរញ្ញវត្ថុឆ្នាំ ២០០៧-២០០៨។ បន្ទាប់មក វិបត្តិកូវីដ-១៩ បានបង្ខំឱ្យរដ្ឋាភិបាលចិនបន្ធូរបន្ថយលក្ខខណ្ឌក្នុងការផ្តល់កម្ចីដល់ក្រុមហ៊ុនឯកជន ដើម្បីទប់ទល់នឹងវិបត្តិនេះ។ ជាលទ្ធផលបំណុលរបស់

ចិនកាលពីឆ្នាំ២០២០ បានកើនឡើងដល់កំណត់ត្រាខ្ពស់បំផុត (record levels) បើធៀបទៅនឹងទំហំសេដ្ឋកិច្ចរបស់ចិន។

យោងតាមទិន្នន័យរបស់ Bank of International Settlements បានបង្ហាញថា មុនពេលដែលកម្រិតនៃបំណុលរបស់ចិនឈានដល់ ២៩០% នៃផ.ស.ស ស្ថានភាពបំណុលរបស់ចិនមានស្ថិរភាពអស់រយៈពេលជាច្រើនឆ្នាំ។ ប៉ុន្តែបំណុលរបស់ប្រទេសដែលមានសេដ្ឋកិច្ចធំៗនៅក្នុងពិភពលោក ដូចជា សហរដ្ឋអាមេរិក ជប៉ុន និងបំណុលនៅប្រទេសក្នុងតំបន់អឺរ៉ុបផ្សេងទៀតក៏មានការកើនឡើងដែរ បើធៀបទៅនឹង ផ.ស.ស។ បំណុលរបស់ប្រទេសទាំងនេះ មានការកើនឡើងដោយសារតែរដ្ឋាភិបាលត្រូវបង្កើនការចំណាយ ដើម្បីទ្រទ្រង់ដល់សកម្មភាពពាណិជ្ជកម្ម និងដើម្បីជួយដល់គ្រួសារដែលទទួលរងផលប៉ះពាល់ដោយសារវិបត្តិកូវីដ១៩។ ទោះយ៉ាងណាស្ថានភាពបំណុលរបស់ចិនមិនដូចបំណុលរបស់សហរដ្ឋអាមេរិក និងជប៉ុនទេ ព្រោះនៅប្រទេសចិន បំណុលអាជីវកម្មមានទំហំធំជាងគេបើធៀបទៅនឹងបំណុលសរុប គឺស្មើនឹងជាង១៦០% នៃ ផ.ស.ស នេះបើយោងតាមទិន្នន័យរបស់ BIS។ រីឯ សហរដ្ឋអាមេរិក និងជប៉ុន បំណុលរបស់រដ្ឋាភិបាល គឺជាបំណុលដែលមានទំហំធំជាងគេនៃបំណុលសរុបទៅវិញ។

គួររំលឹកថា នៅក្នុងរយៈពេលប៉ុន្មានខែនេះ ក្នុងអំលុងពេលដែលសេដ្ឋកិច្ចរបស់ចិនកំពុងតែងើបឡើងវិញ បន្ទាប់ពីរងគ្រោះដោយសារតែវិបត្តិកូវីដ១៩ ចិនបានបន្តកិច្ចខិតខំប្រឹងប្រែងគ្រប់គ្រងបំណុលឡើងវិញ។ ការខិតខំប្រឹងប្រែងនេះបានផ្តល់លទ្ធផលមួយចំនួន ដូចជាបានជួយឱ្យកំណើនហិរញ្ញប្បទានសង្គមរបស់ចិនធ្លាក់ចុះនៅក្នុងខែឧសភា ក្នុងអត្រាកំណើន ១១% ទាបជាងខែមេសាដែលមានអត្រាកំណើន១១,៧%។ មួយវិញទៀតបើយោងតាមការព្យាករណ៍របស់អ្នកសេដ្ឋកិច្ចនៅធនាគារ Barclays នាប្រទេសអង់គ្លេសចុងឆ្នាំនេះ កំណើនឥណទានរបស់ចិន នឹងអាចកើនឡើងក្នុងអត្រាពី ១០% ទៅ ១០,៥% ទាបជាងកំណើននៅចុងឆ្នាំ ២០២០ ដែលមានអត្រាកំណើនដល់ទៅ ១៣,៣%។

សរុបមកបន្ទាប់ពីវិបត្តិហិរញ្ញវត្ថុឆ្នាំ២០០៨ ចិនបានប្រើបំណុលជំរុញកំណើនសេដ្ឋកិច្ចរបស់ខ្លួនឱ្យហក់ឡើងខ្ពស់ជាងជប៉ុន និងបានប្រែក្លាយខ្លួនជាប្រទេសដែលមានសេដ្ឋកិច្ចធំលំដាប់ទី២ នៅក្នុងពិភពលោកនៅឆ្នាំ ២០១០។ ឥឡូវនេះចិនកំពុងបន្តប្រែក្លាយខ្លួនជាប្រទេសដែលមានសេដ្ឋកិច្ចជឿនលឿន ដោយរំពឹងថា នៅឆ្នាំ ២០៣៥ ខ្លួននឹងអាចពង្រីកទំហំសេដ្ឋកិច្ច និងបង្កើនចំណូលរបស់ប្រជាពលរដ្ឋទ្វេដង។ ប៉ុន្តែអ្នកសង្កេតការណ៍មួយចំនួនយល់ឃើញថា ចិនប្រហែលជាទំនងមិនអាចសម្រេចគោលដៅនេះបានទេ ព្រោះតែរដ្ឋាភិបាលកំពុងតែចាត់វិធានការណ៍កាត់បន្ថយបំណុលដែលជាហេតុនាំឱ្យសេដ្ឋកិច្ចចិន អាចនឹងធ្លាក់ចុះក្នុងអំលុងពេលប៉ុន្មានឆ្នាំខាងមុខនេះ។ ខណៈដែលការជំរុញកំណើនសេដ្ឋកិច្ចដោយពឹងផ្អែកលើការប្រើប្រាស់របស់ចិនផ្តល់លទ្ធផលតិចតួច។ ប៉ុន្តែទន្ទឹមនឹងនេះមានទស្សនៈផ្សេងទៀតយល់ឃើញថា ឧបសគ្គទាំងនោះអាចធ្វើឱ្យកំណើនសេដ្ឋកិច្ចរបស់ចិនយឺត ប៉ុន្តែមិនអាចបន្ទុចបង្អាក់ដល់ក្តីសុបិន្តរបស់ចិនបានទេ ព្រោះវាគ្រាន់តែជាអំលុងពេល

មួយដែលចិនត្រូវឆ្លងកាត់មុនពេលក្លាយជាមហាអំណាចសេដ្ឋកិច្ចទីមួយលើពិភពលោកប៉ុណ្ណោះ៕

*ដោយ វង្ស ច័ន្ទស្មើដារា*

*ប្រភព៖ គេហទំព័រ CNBC ចេញផ្សាយថ្ងៃទី២៨ ខែមិថុនា ឆ្នាំ ២០២១*

## អត្រាគ្មានការងារធ្វើនៅជប៉ុនកើនឡើងដល់ ៣%នៅក្នុងខែឧសភា



*ប្រភព៖ CNC ២០២១*

រដ្ឋាភិបាលជប៉ុន នៅថ្ងៃអង្គារនេះ បានប្រកាសថា អត្រាគ្មានការងារធ្វើនៅក្នុងប្រទេសជប៉ុនគឺស្ថិតក្នុងរង្វង់ ៣%នៅក្នុងខែឧសភា កើនឡើងចំនួន ២០%បើប្រៀបធៀបនឹងខែមេសា។

យោងតាមទិន្នន័យរបស់រដ្ឋាភិបាល ចំនួនពលរដ្ឋដែលគ្មានការងារធ្វើនៅក្នុងប្រទេសជប៉ុនក្នុងខែទី៥ ឆ្នាំ២០២១នេះ មានចំនួនប្រហែល ២លាន១១ម៉ឺននាក់ ដោយបានកើនឡើងចំនួន១៣ម៉ឺននាក់ ត្រូវជា ៦,៦% បើធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំ២០២០។

ចំណែកពលរដ្ឋ មានការងារធ្វើនៅក្នុងប្រទេសជប៉ុនកាលពីខែមុនគឺមានចំនួនប្រមាណជា ៦៧លាននាក់ កើនឡើង១១ម៉ឺននាក់ ឬប្រមាណជា ០,២%បើប្រៀបធៀបនឹងខែដូចគ្នានៃឆ្នាំ២០២០។

តួលេខអ្នកអត់ការងារធ្វើនៅក្នុងប្រទេសជប៉ុនបានកើនឡើង ចាប់តាំងពីការចាប់ផ្តើមនៃការឆ្លងរាតត្បាតរបស់វីរុសកូវីដ-១៩ ដែលបានបណ្តាលឱ្យបាត់បង់ការងារជាច្រើនកន្លែង ជាពិសេសនៅក្នុងវិស័យសេវាកម្មដែលរងផលប៉ះពាល់ខ្លាំងបំផុតពីការដាក់ឲ្យអនុវត្តវិធានការរឹតបន្តឹង ដើម្បីទប់ទល់ការឆ្លងនៅក្នុងប្រទេសមួយនេះដែលជាមហាអំណាចសេដ្ឋកិច្ចធំជាងគេលំដាប់ទីបីនៅលើពិភពលោក៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព៖ CNC ចេញផ្សាយថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២១*

## ទិន្នន័យស្រាវជ្រាវសម្រាប់សប្តាហ៍បន្ទាប់

**ថ្ងៃចន្ទ ទី០៥ ខែកក្កដា ឆ្នាំ២០២១**

- កំណើនទុនបម្រុងបរទេសនៅកូរ៉េខាងត្បូង ក្នុងខែឧសភា ឆ្នាំ ២០២១
- IHS Markit Australia Composite PMI បានថយចុះ ក្នុងខែមិថុនាឆ្នាំ ២០២១
- កំណើននៃការលក់រាយនៅអូស្ត្រាលី បានធ្លាក់ចុះក្នុងមួយខែៗ ពិសេសក្នុងខែឧសភាឆ្នាំ ២០២១

**ថ្ងៃអង្គារ ទី០៦ ខែកក្កដា ឆ្នាំ២០២១**

- កំណើននៃការចំណាយក្នុងគ្រួសារជប៉ុន ប្រៀបធៀបទៅនឹងឆ្នាំមុន

- ការថយចុះ ការលក់យានយន្តសរុបនៅសហរដ្ឋអាមេរិក ក្នុងខែឧសភា ធៀបនឹងខែមេសាឆ្នាំ ២០២១
- ការធ្លាក់ចុះនៃការបញ្ជាទិញពីរោងចក្រនៅប្រទេសអាឡឺម៉ង់ ក្នុងមួយខែ ៗ ក្នុងខែមេសា ឆ្នាំ ២០២១

## ថ្ងៃពុធ ទី០៧ ខែកក្កដា ឆ្នាំ២០២១

- អតិរេកគណនីចរន្តរបស់ប្រទេសកូរ៉េខាងត្បូង ក្នុងខែឧសភាឆ្នាំ ២០២១
- ផលិតកម្មឧស្សាហកម្មនៅប្រទេសអាឡឺម៉ង់ បានធ្លាក់ចុះ ១% ពីមួយខែទៅមួយខែ ក្នុងខែមេសាឆ្នាំ ២០២១
- កំណើនទុនបម្រុង រូបិយប័ណ្ណបរទេសនៅអាហ្វ្រិកខាងត្បូង ក្នុងខែឧសភា

## ថ្ងៃព្រហស្បតិ៍ ទី០៨ ខែកក្កដា ឆ្នាំ២០២១

- កំណើនផលិតកម្មឧស្សាហកម្មនៅអាហ្សង់ទីន បានកើនឡើងខ្ពស់បំផុត កាលពីខែមេសាឆ្នាំ ២០២១
- អតិរេកពាណិជ្ជកម្មអាល្លឺម៉ង់ បានកើនឡើងយ៉ាងខ្លាំង ក្នុងខែមេសាឆ្នាំ ២០២១
- កំណើននៃការលក់រថយន្តថ្មីនៅប្រទេសរុស្ស៊ី ពីមួយឆ្នាំទៅមួយឆ្នាំ ពិសេសក្នុងខែឧសភាឆ្នាំ ២០២១

## ថ្ងៃសុក្រ ទី០៩ ខែកក្កដា ឆ្នាំ២០២១

- សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់នៅប្រទេសចិន បានថយចុះ ០,២០ ភាគរយនៅក្នុងខែឧសភា ឆ្នាំ ២០២១ ធៀបនឹងខែមុន។
- ឱនភាពពាណិជ្ជកម្មចក្រភពអង់គ្លេស បានធ្លាក់ចុះ នៅខែមេសាឆ្នាំ ២០២១
- កំណើនសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់នៅប្រទេស ប្រេស៊ីល នៅក្នុងខែឧសភាឆ្នាំ ២០២១ ធៀបនឹងខែមុន៕